**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ ៣៦៩/២១ ក. ស. ភ.

ថ្ងៃពុធ ១រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព. ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២១

# សេចក្តីប្រកាសព័ត៌មាន

**កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)** មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា នៅព្រឹកថ្ងៃចន្ទ ១៤កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ ក. ស. ភ. បានរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ **"ហេដ្ឋារចនាសម្ព័ន្ធចំណតផែកុងតឺន័រ LM១៧ ជំហានទី៣ ដំណាក់កាលទី១"** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន** និងមានការអញ្ជើញចូលរួមពី **ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល**, ថ្នាក់ដឹកនាំនៃក្រសួងសាធារណការ និងដឹកជញ្ជូន, សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ., អាជ្ញាធរពាក់ព័ន្ធ, ថ្នាក់ដឹកនាំ ក. ស. ភ. និងភ្ញៀវកិត្តិយសដែលជាក្រុមហ៊ុនដៃគូ ដោយបានគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល តាមរយៈការរក្សាគម្លាត ការពាក់ម៉ាស និងអនុវត្ត ៣ កុំ និង ៣ ការពារ។

ការពង្រីកហេដ្ឋារចនាសម្ព័ន្ធនៃចំណតផែកុងតឺន័រ LM១៧ ជំហានទី៣ ដំណាក់កាលទី១ នេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីឆ្លើយតបនឹងកំណើនកុងតឺន័រឆ្លងកាត់ជាបន្តបន្ទាប់ ដែលលើសពីសមត្ថភាពផ្ទុកចំនួន ៣០០ ០០០ TEUs នៃចំណតផែកុងតឺន័រ ជំហានទី១ និងជំហានទី២។ កំណើនកុងតឺន័រឆ្លងកាត់ ក. ស. ភ. ជាមធ្យមប្រចាំឆ្នាំមានចន្លោះពី ១៥% ទៅ ១៨%។ ជាក់ស្តែង នៅឆ្នាំ២០១៩ បរិមាណកុងតឺន័រឆ្លងកាត់មានចំនួន ២៨១ ០៤៣ TEUs និងនៅឆ្នាំ ២០២០ មានចំនួន ២៩០ ៨៥៧ TEUs ទោះបីជាមានវិបត្តិ ដែលកើតឡើងដោយជម្ងឺកូវីដ-១៩ ក៏ដោយ។ ដូច្នេះហើយ ទើបនៅចុងឆ្នាំ២០១៩ ក. ស. ភ. បានអនុវត្តគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធនៃចំណតផែកុងតឺន័រ LM១៧ ជំហានទី៣ ដំណាក់កាលទី១ នេះ ដែលបង្កើនសមត្ថភាពផ្ទុកចំនួន ១០០ ០០០ TEUs ក្នុងមួយឆ្នាំ បន្ថែមទៀត ហើយបច្ចុប្បន្ន ចំណតផែកុងតឺន័រ LM១៧ មានសមត្ថភាពផ្ទុកសរុបចំនួន **៤០០ ០០០ TEUs** ក្នុងមួយឆ្នាំ។

ការពង្រីកហេដ្ឋារចនាសម្ព័ន្ធនៃចំណតផែកុងតឺន័រ LM១៧ ជំហានទី៣ ដំណាក់កាលទី១ ធ្វើនៅលើផ្ទៃដីទំហំ ២,៧៥ ហិកតា ស្ថិតនៅភាគខាងជើងនៃចំណតផែកុងតឺន័រ LM១៧ ជំហានទី១ និងទី២ ដោយបានប្រើប្រាស់ទុនវិនិយោគផ្ទាល់របស់ ក. ស. ភ. ប្រមាណ ១៨,៤ លានដុល្លារអាមេរិក ដែលបានមកពីប្រាក់ចំណេញ និងប្រាក់សន្សំអភិវឌ្ឍសហគ្រាស។ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធនេះរួមមាន ការសាងសង់ទីលានផ្ទុកកុងតឺន័រទំហំ ២,៧៥ ហិកតា ការងារសាងសង់ស្ពានផែទំហំ ១២ម×១៤៩ម ការងារសាងសង់ច្រកទ្វារចេញចូលថ្មីទំហំ ២១ម×៣០ម ការបំពាក់រថស្ទូចលើទីលានប្រភេទ RTG ចំនួន ៤ គ្រឿងបន្ថែម ការបំពាក់ដងយោង FCC ចំនួន ២គ្រឿង ការបំពាក់គ្រឿងចក្រលើកដាក់ Empty Stacker ចំនួន ២ គ្រឿង ការបំពាក់រថយន្តដឹកកុងតឺន័រក្នុងផៃ Terminal Tractor ចំនួន ១០គ្រឿង និងការបំពាក់ម៉ាស៊ីនភ្លើងសម្រាប់ផ្គត់ផ្គង់ដងយោង FCC និងទីលានផ្ទុកកុងតឺន័រជំហានទី២ និងទី៣។

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តីរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh

ជាជំហានបន្ទាប់ ក្រោយពីចំណតផែកុងតឺន័រ LM១៧ ជំហានទី៣ ដំណាក់កាលទី១ បានបញ្ចប់ ក. ស. ភ. នឹងបន្តអនុវត្តគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធនៃចំណតផែកុងតឺន័រ LM១៧ ជំហានទី៣ ដំណាក់កាលទី២ ចន្លោះពីឆ្នាំ ២០២២ ដល់ឆ្នាំ២០២៣ ដោយធ្វើការពង្រីកទីលានផ្ទុកកុងតឺន័របន្ថែម និងការបំពាក់ RTG ចំនួន ៤គ្រឿង លើផ្ទៃដីសរុបទំហំ ២,៧៥ ហិកតា (អាចបង្កើនសមត្ថភាព ១០០ ០០០ TEUs ក្នុងមួយឆ្នាំ) ដែលនឹងនាំឱ្យសមត្ថភាពផ្ទុកកុងតឺន័រសរុបរបស់ចំណតផែកុងតឺន័រ LM១៧ មានចំនួន ៥០០ ០០០ TEUs ក្នុងមួយឆ្នាំ។ លើសពីនេះ ប្រសិនបើបរិមាណកុងតឺន័រឆ្លងកាត់ នៅតែមានកំណើនជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ ក. ស. ភ. បានត្រៀមបម្រុងទុកផ្ទៃដីទំហំប្រមាណ ៩ ហិកតា ដែលមានទីតាំងស្ថិតនៅខាងត្បូងនៃចំណតផែកុងតឺន័រ LM១៧ សម្រាប់ធ្វើការអភិវឌ្ឍទីលានផ្ទុកកុងតឺន័រជំហានទី៤ (២០២៤-២០៣០) ដើម្បីបង្កើនសមត្ថភាពផ្ទុកកុងតឺន័រឱ្យបាន ៤០០ ០០០ TEUs ក្នុងមួយឆ្នាំបន្ថែមទៀត ដែលនាំឱ្យសមត្ថភាពផ្ទុកកុងតឺន័រសរុប រហូតដល់ ៩០០ ០០០ TEUs ក្នុងមួយឆ្នាំ នៅឆ្នាំ២០៣០។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**